**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ៤៦៤.....សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការណែនាំអនុវត្តភាគពុកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ១១០ សសរ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់គ្រប់គ្រងសកម្មភាពការងារអង្គការមិនមែនរដ្ឋាភិបាលបរទេស
- បានឃើញប្រកាសលេខ ១០៥៩ ប្រក.សហវ.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណូលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៩៦ សហវ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជីពន្ធដារ
- យោងតាមការចាំបាច់នៃការគ្រប់គ្រងប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

### ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងពង្រឹងការអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ២.- គោលដៅ

ប្រកាសនេះ មានគោលដៅផ្តល់ការណែនាំបន្ថែមអំពីការបំពេញកាតព្វកិច្ចសារពើពន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលស្របទៅតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន និងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបន្តធានាការអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

### ប្រការ ៣.- វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ៤.- និយមន័យ

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "**សមាគម**" សំដៅដល់អង្គការសមាជិកភាព ឬអង្គការដែលមានលក្ខណៈប្រហាក់ប្រហែលដែលត្រូវបានបង្កើតឡើងដោយរូបវន្តបុគ្គល ឬ/និងនីតិបុគ្គល ក្នុងគោលបំណងធ្វើជាតំណាង និងការពារផលប្រយោជន៍របស់សមាជិកខ្លួនដោយមិនទាញយកចំណេញ ឬមិនយកកម្រៃមកចែកគ្នា។ ពាក្យ "**សមាគម**" រួមបញ្ចូលផងដែរនូវសភាពាណិជ្ជកម្ម ឧស្សាហកម្ម ឬកសិកម្ម។ សម្រាប់គោលដៅនៃប្រកាសនេះ សមាគមដែលបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហៅថា "**សមាគមក្នុងស្រុក**" រីឯ សមាគមដែលបង្កើតឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជា ហៅថា "**សមាគមបរទេស**"។

២- ពាក្យ "**អង្គការមិនមែនរដ្ឋាភិបាល**" សំដៅដល់អង្គការមិនមែនសមាជិកភាព ឬអង្គការដែលមានលក្ខណៈប្រហាក់ប្រហែល រួមទាំងមូលនិធិដែលត្រូវបានបង្កើតឡើងដោយរូបវន្តបុគ្គល ឬ/និងនីតិបុគ្គលក្រៅពីស្ថាប័នរដ្ឋាភិបាល

ក្នុងគោលបំណងផ្តល់មូលនិធិ ឬសេវាកម្ម លើវិស័យមួយឬច្រើនដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយមិនទាញយកចំណេញឬមិនយកកម្រៃមកចែកគ្នា។ សម្រាប់គោលដៅនៃប្រកាសនេះ អង្គការមិនមែនរដ្ឋាភិបាលដែលបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហៅថា "**អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក**" រីឯ អង្គការដែលបង្កើតឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជា ហៅថា "**អង្គការមិនមែនរដ្ឋាភិបាលបរទេស**"។

**ប្រការ ៥.~ ការចុះបញ្ជីពន្ធដារ**

អនុលោមមាត្រា ៣ ថ្មី និងមាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវមានកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធអនុលោមតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ប្រការ ៦.~ ការលើកលែងពន្ធលើប្រាក់ចំណូល**

អនុលោមតាមមាត្រា ៩ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ពន្ធលើប្រាក់ចំណូលត្រូវបានលើកលែងចំពោះប្រាក់ចំណូលរបស់÷

១- អង្គការមិនមែនរដ្ឋាភិបាលណាមួយ ដែលត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រឬអប់រំ ហើយគ្មានចំណែកណាមួយនៃទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។

២- សមាគមណាមួយ ក្នុងករណីដែលប្រាក់ចំណូលរបស់សមាគមទាំងនោះ មិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុនឬរូបវន្តបុគ្គល។

ប្រាក់ចំណូលដែលត្រូវបានលើកលែងពន្ធ ក្នុងប្រការនេះ រួមមាន មូលនិធិឬអំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល ធនធាននិងទ្រព្យសម្បត្តិរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាល ភាគទានឬវិភាគទានឬបរិវិសទានរបស់សមាជិក និងចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត វៀរលែងតែ ប្រាក់ចំណូលពីសកម្មភាពអាជីវកម្មដោយឡែកដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ។

**ប្រការ ៧.~ ការទទួលបាន និងការបាត់បង់លក្ខណសម្បត្តិលើកលែងពន្ធលើប្រាក់ចំណូល**

១- ដើម្បីទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងប្រការ ៦ នៃប្រការនេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវដាក់ពាក្យស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារតាមទម្រង់ដែលបានកំណត់ និងត្រូវភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃឯកសារដូចខាងក្រោម÷

- ក- លក្ខន្តិកៈ និងលិខិតអនុញ្ញាតចុះបញ្ជីនៅក្រសួងមហាផ្ទៃ សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬ
- ខ- អនុស្សរណៈជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស។

២- សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវជូនដំណឹងទៅអគ្គនាយកដ្ឋានពន្ធដារ អំពីការផ្លាស់ប្តូរលក្ខខណ្ឌនានា ដែលបានចុះបញ្ជាក់នៅក្នុងពាក្យស្នើសុំលើកលែងពន្ធលើប្រាក់ចំណូល ក្នុងអំឡុងពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការក្រោយមានការផ្លាស់ប្តូរ។

៣- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបាត់បង់លក្ខណសម្បត្តិលើកលែងពន្ធ ប្រសិនបើមិនគោរពតាមលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ ឬមានភស្តុតាងថាបានប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា ១២៨ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៨.- សកម្មភាពដែលមិនស្ថិតក្នុងគោលដៅសុទ្ធសាធរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល**

១- សកម្មភាពរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលមួយដែលមិនស្ថិតក្នុងគោលដៅសុទ្ធសាធ ដូចមានចែងក្នុងកថាខណ្ឌ ក នៃប្រការ ៦ នៃប្រកាសនេះ ដើម្បីស្វែងរកប្រាក់ចំណូល ឬមូលនិធិ ត្រូវបានចាត់ទុកថាជាសកម្មភាពអាជីវកម្មដោយឡែក និងត្រូវជាប់ពន្ធតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

ឧទាហរណ៍ ៨.១÷

អង្គការមិនមែនរដ្ឋាភិបាល ក ត្រូវបានបង្កើតឡើងក្នុងគោលដៅអភិវឌ្ឍន៍ និងជួយកុមារកំព្រា និងជនអនាថា ដោយធ្វើសកម្មភាពអប់រំ បណ្តុះបណ្តាល ដោយមិនយកកម្រៃនូវអក្សរសាស្ត្រ មុខជំនាញខាងចុងភៅ បដិសណ្ឋារកិច្ច និងជួសជុលម៉ូតូ។ ដើម្បីផ្តល់ឱ្យសិស្សនូវការអនុវត្តជាក់ស្តែង អង្គការបានបង្កើតជាភោជនីយដ្ឋានមួយ និងរោងជាងជួសជុលម៉ូតូមួយ សម្រាប់បម្រើអតិថិជន ដោយបុគ្គលិក និងចុងភៅ សុទ្ធតែជាគ្រូបណ្តុះបណ្តាល និងសិក្ខាកាមនៅក្នុងអង្គការនោះ។ ចំណូលដែលទទួលបានពីភោជនីយដ្ឋាន និងរោងជាងជួសជុល ត្រូវបានប្រើប្រាស់សម្រាប់ជួយទ្រទ្រង់សកម្មភាពរបស់ខ្លួន។

ឧទាហរណ៍ ៨.២÷

សមាគម ខ ត្រូវបានបង្កើតឡើងក្នុងគោលដៅអភិវឌ្ឍន៍ដំណាំកសិកម្មដែលមានសកម្មភាពសិក្សាស្រាវជ្រាវបណ្តុះពូជរុក្ខជាតិផ្សេងៗ។ សមាគម ខ បានបើកសាលាមួយដើម្បីបណ្តុះបណ្តាលសិក្ខាកាម ដោយយកប្រាក់កម្រៃ។ ចំណូលពីសាលាបណ្តុះបណ្តាល ត្រូវបានយកមកទ្រទ្រង់សកម្មភាពរបស់សមាគម។

ក្នុងឧទាហរណ៍ទាំងពីរខាងលើនេះ សកម្មភាពភោជនីយដ្ឋាន រោងជាងជួសជុលម៉ូតូ និងសាលាបណ្តុះបណ្តាល ត្រូវចាត់ទុកជាសកម្មភាពអាជីវកម្មដោយឡែក ហើយប្រាក់ចំណូលពីសកម្មភាពអាជីវកម្មទាំងនេះ ត្រូវជាប់ពន្ធលើប្រាក់ចំណូល។

២- សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដូចក្នុងកថាខណ្ឌ ១ នៃប្រការនេះ ត្រូវមានកាតព្វកិច្ចចុះបញ្ជីពន្ធដារ និងកត់ត្រាបញ្ជីកាគណនេយ្យដោយឡែកសម្រាប់សកម្មភាពអាជីវកម្មដែលមិនស្ថិតក្នុងគោលដៅសុទ្ធសាធរបស់ខ្លួន។

៣- សកម្មភាពអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងប្រការនេះ ត្រូវស្ថិតនៅក្នុងប្រភេទអ្នកជាប់ពន្ធណាមួយទៅតាមកម្រិតផលរបរប្រចាំឆ្នាំ ដែលមានចែងក្នុងប្រកាសលេខ ០២៥ សហវ.ប្រក.អពដ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨។

**ប្រការ ៩.- កាតព្វកិច្ចពន្ធ-អាករដទៃទៀត**

ក្រៅពីពន្ធលើប្រាក់ចំណូល សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបំពេញកាតព្វកិច្ចជាភ្នាក់ងារកាត់ទុកស្របតាមមាត្រា ២៥ ថ្មី មាត្រា ២៦ ថ្មី (មួយ) និងមាត្រា ៣១ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ និងបង់ពន្ធលើប្រាក់បៀវត្សព្រមទាំងពន្ធនិងអាករដទៃទៀតស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ប្រការ ១០.~ ការដាក់លិខិតប្រកាសពន្ធ**

សមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវដាក់លិខិតប្រកាសពន្ធប្រចាំខែ ប្រចាំឆ្នាំ សម្រាប់សកម្មភាពជាគោលដៅ និងសកម្មភាពអាជីវកម្មដោយឡែក តាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ ទោះបីជាមានឬគ្មានប្រាក់ពន្ធត្រូវបង់ក៏ដោយ។

ចំពោះលិខិតប្រកាសពន្ធប្រចាំឆ្នាំ ត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធជាអាទិ៍មាន ព័ត៌មានគណនីធនាគារ របាយការណ៍ហិរញ្ញវត្ថុ កិច្ចព្រមព្រៀងហិរញ្ញប្បទាន ផែនការគម្រោងសកម្មភាព របាយការណ៍សកម្មភាពអនុវត្តគម្រោង និងឯកសារពាក់ព័ន្ធដទៃទៀត។

**ប្រការ ១១.~ និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១២.~ ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកឬអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋានអគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវអនុវត្តខ្លឹមសារនៃប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៨

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ១២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ